# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ធំៗលើពិភពលោក និងបណ្ដាប្រទេសនៅអាស៊ីបូព៌ា។

ភាពមិនប្រាកដប្រជា នៃបរិយាកាសសេដ្ឋកិច្ចពិភពលោក បានបន្តរារាំងដល់កិច្ចប្រឹងប្រែងជំរុញសេដ្ឋកិច្ច ឲ្យរើបឡើងវិញ នៅបណ្ដាប្រទេសនៅតំបន់អាស៊ីបូព៌ា និងប្រទេសឧស្សាហកម្មធំៗ ដោយការប្រមើលពីកំណើននៅត្រីមាសទី១ ឆ្នាំ២០១២ នេះ វាប្រែប្រួលឡើងចុះខ្លាំងជាងនៅត្រីមាសមុន និងត្រីមាសដូចគ្នាឆ្នាំមុន។

កំណើន ផសស ពិតនៅឥណ្ឌូនេស៊ី ធ្លាក់ចុះបន្តិច មកត្រឹម ៦,៣% ធៀបនឹង ៦,៥% កាលពីឆ្នាំមុន។ កំណើន ផសស នៅម៉ាឡេស៊ី ធ្លាក់ចុះនៅត្រីមាសទី១ មកត្រឹម ៤,៧% ធៀបនឹង ៥,២% កាលពីត្រីមាសមុន។ សេដ្ឋកិច្ចនៅប្រទេសខ្លះអាស៊ីមួយចំនួន បន្តធ្លាក់ចុះទៀត។ កំណើន ផសស ពិត នៅសិង្ហបុរី ធ្លាក់ចុះមកត្រឹម ១,៦% ធៀបនឹង ៦,៨% កាលពីឆ្នាំមុន។ កំណើន ផសស នៅ ហុងកុង និង តៃវ៉ាន់ រួមចុះមកត្រឹម ០,៤% ដែលជាអត្រាទាបបំផុត គិតចាប់ពីឆ្នាំ២០១០ មក។ សេដ្ឋកិច្ចប្រទេសថៃ រើបឡើងវិញមកត្រឹមកម្រិតកាលពីមួយឆ្នាំមុន បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុកនៅត្រីមាសទី៤ ឆ្នាំ២០១១។ មូលនិធិរូបិយវត្ថុអន្តរជាតិមានសុទិដ្ឋិនិយមថា សេដ្ឋកិច្ចថៃ នឹងស្ទុះឡើងវិញដល់ ៥,០% នៅឆ្នាំនេះ និង ៥,៥% នៅឆ្នាំ២០១៣។ នៅត្រីមាសទី១ សេដ្ឋកិច្ចប្រទេសចិន កើនឡើងយឺតជាងមុន ប៉ុន្តែនៅមានកម្រិតខ្ពស់ដដែល គឺ ៨,១% ធៀបនឹង ៩,៧% កាលពីឆ្នាំមុន។ កូរ៉េខាងត្បូង មានកំណើន ផសស ៣,០% ធៀបនឹង ៤,២% កាលពីឆ្នាំមុន។

នៅត្រីមាសទី១ ឆ្នាំ២០១២ កំណើនសេដ្ឋកិច្ចនៅតំបន់អឺរ៉ូ រួមចុះដល់សូន្យ ដែលជាកម្រិតទាបបំផុត គិតចាប់ពីឆ្នាំ២០១០ មក។ ថ្នាក់ដឹកនាំនៅបណ្ដាប្រទេសអឺរ៉ុប កំពុងប្រឹងដោះស្រាយវិបត្តិបំណុលនៅប្រទេសក្រិច និងបញ្ហានៅប្រទេសជាសមាជិកសហភាពអឺរ៉ុបដទៃទៀត។ បន្ទាប់ពីទទួលបានកញ្ចប់ប្រាក់ជានាចំនួនបី និងអនុវត្តវិធានការត្បិតត្បៀតចំណាយ ប្រទេសក្រិចត្រូវប្រឹងថែមទៀតដើម្បីស្ដារទំនុកចិត្តអាជីវកម្ម និងវិនិយោគិនឡើងវិញ។ ការបោះឆ្នោតនៅខែមិថុនា អាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ប្រទេសក្រិច ក្នុងការអនុវត្តវិធានការរឹតត្បិតចំណាយបន្ថែម ដើម្បីអាចទទួលបានកញ្ចប់ប្រាក់ជានាមួយទៀត ហើយបញ្ហានេះ អាចធ្វើឲ្យក្រិចត្រូវចាកចេញពីតំបន់អឺរ៉ូ។ គេក៏កំពុងផ្ដោតការយកចិត្តទុកដាក់ លើស្ថានភាពមិនល្អនៃលទ្ធភាពសងបំណុលរបស់ធនាគារនៅប្រទេសអេស្ប៉ាញដែរ។

សេដ្ឋកិច្ចសហរដ្ឋអាមេរិក មានដំណើរការល្អដោយមានកំណើន ២,១% នៅត្រីមាសទី១ ឆ្នាំ២០១២។ សេដ្ឋកិច្ចជប៉ុនមានកំណើនវិជ្ជមានវិញ ដល់ ២,៧% បន្ទាប់ពីមានកំណើនអវិជ្ជមាន ឬមានកំណើនសូន្យតាំងពីឆ្នាំ២០១១ មក។ ទោះជាយ៉ាងនេះក្ដី ប្រទេសជប៉ុននៅតែត្រូវបន្តដោះស្រាយបញ្ហាភាពទន់ខ្សោយនៃតម្រូវការពិភពលោក នូវទំនិញប្រើប្រាស់របស់ជប៉ុន ការឡើងថ្លៃប្រាក់យេន ការកសាងសេដ្ឋកិច្ចឡើងវិញ ក្រោយស៊ូណាមិ និងការបង្កើតគោលនយោបាយថាមពល បើសិនជប៉ុនសម្រេចចិត្តមិនប្រើថាមពលនុយក្លេអ៊ែរ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១១ អតិផរណានៅកម្ពុជាកើនដល់ ៥,៥% ធៀបនឹង ៣,៦% កាលពីឆ្នាំមុន។ ថ្លៃប្រេងក្នុងស្រុក និងអតិផរណាខ្ពស់នៅប្រទេសជិតខាង ដូចជា វៀតណាម ជាដើម បានជះឥទ្ធិពលបន្ថែមទៀត លើថ្លៃប្រេងលក់រាយនៅកម្ពុជា ដោយសារការធ្វើសមាហរណកម្មទីផ្សារផលិតផល។ នៅត្រីមាសទី១ វៀតណាមបន្តមានអតិផរណាខ្ពស់ដដែល ដល់ ១៦,០% បើធៀបនឹង ១២,៨% នៅត្រីមាសដូចគ្នាឆ្នាំមុន។ អត្រាអតិផរណានៅអាស៊ីបូព៌ា និងបណ្ដាប្រទេសឧស្សាហកម្ម មានកម្រិតសមរម្យ។ នៅត្រីមាសទី១ ឆ្នាំ២០១២ អតិផរណាប្រចាំឆ្នាំនៅចិន រួមចុះមកត្រឹម ៣,៨% ធៀបនឹង ៥,១% កាលពីឆ្នាំមុន ប៉ុន្តែអតិផរណានៅតំបន់អឺរ៉ូ កើនដល់ ២,៧% ធៀបនឹង ២,៥% កាលពីឆ្នាំមុន។ ក្នុងអំឡុងពេលនេះដែរ ប្រាក់រៀល ធ្លាក់ថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ និង ៤,១% ទល់នឹងប្រាក់អឺរ៉ូ ប៉ុន្តែប្រាក់យេនឡើងថ្លៃ ៣,៨% ទល់នឹងប្រាក់ដុល្លារ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១២ ពោត (US No. 2) ធ្លាក់ថ្លៃ ១,០% បើធៀបនឹងមួយឆ្នាំមុន មកត្រឹម ២៧៧,៥ដុល្លារ/តោន ប្រេងឆា (អឺរ៉ុបភាគពាយ័ព្យ) ធ្លាក់ថ្លៃ ១១,៥% មកត្រឹម ១១០៦,៧ដុល្លារ/តោន ហើយ កៅស៊ូ (SMR 5) ធ្លាក់ថ្លៃ ២៩,៨% មកត្រឹម ៣៧០១,២ដុល្លារ/តោន។ អង្ករ (Thai 100 percent B) ឡើងថ្លៃ ៣,៩% ដល់ ៥៤៥ដុល្លារ/តោន រីឯសណ្ដែកសៀង (US No. 1) ធ្លាក់ថ្លៃ ៨,៦% មកត្រឹម ៤៩០,៨ដុល្លារ/តោន។ សាំង (US Gulf Coast) ឡើងថ្លៃ ១៦,៣% ដល់ ០,៧៨ដុល្លារ/លីត្រ ហើយម៉ាស៊ូត (US Gulf Coast) ឡើងថ្លៃ ១៥,៥% ដល់ ០,៨៤ដុល្លារ/លីត្រ។

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | 0.1 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.2 | 6.2 | 5.8 | 6.9 | 6.5 | 6.5 | 6.5 | 6.5 | 6.3 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -2.4 | 8.9 | 5.3 | 4.8 | 4.6 | 4.0 | 5.8 | 5.2 | 4.7 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -4.5 | 18.7 | 10.5 | 12.0 | 8.3 | 0.9 | 5.9 | 3.6 | 1.6 |
| ថៃ | 4.8 | 4.9 | 2.6 | 3.3 | 9.2 | 6.7 | 3.8 | 3.0 | 2.6 | 3.5 | -9.0 | 0.0 |
| វៀតណាម | 8.1 | 8.5 | 6.2 | 4.7 | 6.4 | 7.2 | 7.3 | 5.4 | 5.7 | 7.2 | 6.1 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 8.2 | 10.3 | 9.7 | 9.8 | 9.7 | 9.5 | 9.1 | 8.9 | 8.1 |
| ហុងកុង | 6.6 | 6.4 | 2.4 | -3.2 | 6.5 | 6.8 | 6.2 | 7.2 | 5.1 | 4.3 | 3.0 | 0.4 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -1.0 | 7.1 | 4.5 | 4.8 | 4.2 | 3.4 | 3.4 | 3.4 | 3.0 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -3.6 | 12.9 | 9.8 | 6.9 | 6.5 | 4.9 | 3.4 | 1.9 | 0.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -3.8 | 1.7 | 1.9 | 2.0 | 2.5 | 1.6 | 1.4 | 0.7 | 0.0 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -5.4 | 3.5 | 5.0 | 2.2 | -1.0 | -1.0 | 0.0 | -1.0 | 2.7 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.5 | 2.9 | 2.3 | 2.8 | 2.3 | 1.5 | 1.6 | 1.6 | 2.1 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | | 4.1 | 1.8 | 3.3 | 3.6 | 6.2 | 6.7 | 4.9 | 5.5 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 4.7 | 4.4 | 6.2 | 6.3 | 6.8 | 5.9 | 4.7 | 4.1 | 3.8 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 0.4 | 1.6 | 1.9 | 2.1 | 2.8 | 3.3 | 3.4 | 3.2 | 2.3 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 0.5 | 3.1 | 3.4 | 4.0 | 5.2 | 4.7 | 5.5 | 5.5 | 4.9 |
| ថៃ | 4.7 | 2.2 | 5.5 | -0.9 | 3.3 | 3.3 | 2.0 | 3.0 | 4.1 | 4.1 | 4.0 | 3.4 |
| វៀតណាម | 7.7 | 8.3 | 23.3 | 7.3 | 9.0 | 8.4 | 10.9 | 12.8 | 19.4 | 22.5 | 19.8 | 16.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.8 | 2.7 | 3.3 | 4.7 | 5.1 | 5.7 | 6.3 | 4.6 | 3.8 |
| ហុងកុង | 2.2 | 2.0 | 4.3 | -0.3 | 2.6 | 2.3 | 2.9 | 4.0 | 5.1 | 6.5 | 5.7 | 5.2 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 2.8 | 2.6 | 2.9 | 3.6 | 4.4 | 4.2 | 4.8 | 4.1 | 2.9 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | -1.1 | 1.1 | 0.4 | 1.1 | 1.3 | 1.6 | 1.3 | 1.4 | 1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 0.4 | 1.5 | 1.7 | 2.0 | 2.5 | 2.7 | 2.7 | 2.9 | 2.7 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -1.3 | -0.9 | -0.9 | 0.1 | 0.0 | 0.3 | 0.2 | -0.3 | 0.3 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.4 | 1.8 | 1.2 | 1.3 | 2.1 | 3.5 | 3.8 | 3.3 | 2.8 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4140.48 | 4236.69 | 4122.58 | 4041.90 | 4044.89 | 4095.66 | 4071.89 | 4045.98 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 10413.83 | 8995.11 | 8965.70 | 8902.02 | 8593.94 | 8625.83 | 8985.65 | 9078.63 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.70 | 3.30 | 3.30 | 3.52 | 3.15 | 3.11 | 3.05 | 3.02 | 3.02 | 3.15 | 3.06 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 1.42 | 1.45 | 1.36 | 1.30 | 1.28 | 1.24 | 1.23 | 1.29 | 1.26 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 34.34 | 31.63 | 29.99 | 30.56 | 30.28 | 30.15 | 30.98 | 31.00 |
| វៀតណាម (ដុង) | 15994.00 | 16030.00 | 16382.00 | 17725.24 | 19485.00 | 19499.48 | 20273.83 | 20693.58 | 20699.60 | 20997.70 | 20971.18 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 7.97 | 8.03 | 6.94 | 6.83 | 6.77 | 6.66 | 6.58 | 6.50 | 6.42 | 6.36 | 6.31 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.77 | 7.76 | 7.79 | 7.78 | 7.79 | 7.78 | 7.76 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1277.76 | 1182.41 | 1132.85 | 1120.19 | 1084.27 | 1084.90 | 1144.87 | 1131.17 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 33.04 | 31.90 | 30.36 | 29.30 | 28.86 | 29.19 | 30.26 | 29.68 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.72 | 0.77 | 0.74 | 0.73 | 0.70 | 0.71 | 0.74 | 0.76 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 93.60 | 85.74 | 82.53 | 82.33 | 81.66 | 77.86 | 77.78 | 79.30 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 167.31 | 176.13 | 238.81 | 280.32 | 311.63 | 302.79 | 270.77 | 277.50 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 686.84 | 874.67 | 1108.00 | 1251.00 | 1147.00 | 1079.00 | 1024.67 | 1106.67 |
| កៅស៊ូ SMR 5 (USD/តោន) | 1996.30 | 2202.30 | 2586.30 | 1884.84 | 3175.97 | 4257.27 | 5278.03 | 4968.77 | 4617.57 | 3658.00 | 3701.17 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 524.47 | 468.33 | 531.00 | 528.25 | 514.33 | 581.3 | 610.33 | 549.00 |
| សណ្ដែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 414.03 | 406.88 | 480.24 | 537.24 | 525.66 | 513.98 | 454.83 | 490.79 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 60.50 | 74.91 | 84.17 | 100.70 | 113.31 | 108.91 | - | - |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 42.91 | 51.54 | 57.23 | 67.92 | 78.73 | 74.63 | 68.50 | 78.97 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 43.05 | 53.64 | 61.68 | 72.47 | 75.72 | 77.27 | 77.31 | 83.75 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[1]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

បរិយាកាសសេដ្ឋកិច្ចសកលនៅអន់ខ្សោយ ដោយសារជាសំខាន់ វិបត្តិហិរញ្ញវត្ថុ និងវិបត្តិបំណុលនៅប្រទេសក្រិច និងនៅប្រទេសអឺរ៉ុបខ្លះទៀតក៏ពិតមែន ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅខ្លាំងក្លាគួរសម ដោយមានកំណើន ផសស ៧,០% នៅឆ្នាំ២០១១។ ដំណើរការសេដ្ឋកិច្ចនៅត្រីមាសទី៤ ឆ្នាំ២០១១ ហាក់បានល្អប្រសើរជាងកាលពីត្រីមាសទី៤ ឆ្នាំ២០១០។ អនុមតិវិនិយោគសរុប គិតជាទ្រព្យសកម្មជាប់លាប់កើន ៩,៦% ធៀបនឹងមួយឆ្នាំមុន ក្នុងនោះ អនុមតិវិនិយោគខាងកសិកម្ម មាន ៣២,៩% ខាងឧស្សាហកម្ម មាន ១៣,១% និងខាងសេវាកម្ម មាន ៥៤,០%។ វិស័យកសិកម្មបានស្ទុះឡើងវិញ ដោយមានកំណើនអនុមតិវិនិយោគ១១០០%ធៀបនឹងមួយឆ្នាំមុនដល់៤៤០,៦លានដុល្លារ។ វិនិយោគខាងឧស្សាហកម្ម កើន ៩៩,៤% ក្នុងនេះផ្នែកសម្លៀកបំពាក់មានចំណែក៦៧,៨%ក្នុងវិនិយោគសរុបដោយមានកំណើន ១៣៧,៤%។ វិនិយោគខាងសេវាកម្ម ធ្លាក់ចុះ ៣៤,១% ធៀបនឹងឆ្នាំមុន មកត្រឹម ៧២២,៦លានដុល្លារ ក្នុងនេះវិនិយោគផ្នែកសណ្ឋាគារ និងទេសចរណ៍ (ស្មើនឹង ៣៥,៦% នៃវិនិយោគសរុប) ធ្លាក់ចុះ ៧៦,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែចំនួនភ្ញៀវទេសចរមកទស្សនាកម្ពុជា កើន ១៣,៩%។ នៅត្រីមាសទី១ ឆ្នាំ២០១១ វិស័យសំណង់បន្តរើបឡើងវិញ ដោយមានតម្លៃអនុមតិវិនិយោគសរុបកើន ៦៣៦,៩% ធៀបនឹងឆ្នាំមុន។

នៅត្រីមាសទី១ នេះដែរ ការនាំចេញបន្តមានដំណើរការរស់រវើក ដោយមានកំណើន ២៥,៨%។ ការនាំចេញសម្លៀកបំពាក់ រួមចំណែក ៨៣,៦% នៃតម្លៃនាំចេញសរុប ឬ កើន ២១,៦%។ សហរដ្ឋអាមេរិក នៅតែជាគោលដៅនាំចេញចម្បងរបស់កម្ពុជា ដោយមានចំណែក ៤៦,១% នៃការនាំចេញសម្លៀកបំពាក់សរុប ហើយបន្ទាប់មក គឺ សហភាពអឺរ៉ុប (៣០,៦%) ដៃគូពាណិជ្ជកម្មដទៃទៀត (១៧,៩%) ជប៉ុន (៤,៦%) និង អាស៊ាន (០,៦%)។ ទោះយ៉ាងនេះក្ដី កំណើនពីមួយឆ្នាំទៅមួយឆ្នាំ នៃការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក (៦,២%) មានទំហំតូចជាងកំណើនការនាំចេញទៅសហភាពអឺរ៉ុប (៤១,៥%) អាស៊ាន (៦៨,៤%) និង ជប៉ុន (៤៦,១%)។ នៅត្រីមាសនេះដែរ ការនាំចេញផលិតផលកសិកម្ម កើន ៨,៨% ក្នុងនេះ ការនាំចេញឈើកើន ៤៣,៥% ហើយការនាំចេញផលិតផល "ផ្សេងៗ" កើន ៧៨,៦%។ ការនាំចេញកៅស៊ូធ្លាក់ចុះ ១៩,២% ហើយការនាំចេញត្រី ធ្លាក់ចុះ ១៦,៦%។ ការនាំចូលសរុប កើន ១១,១% ដល់ ៨០៩,៩លានដុល្លារ ក្នុងនេះ ការនាំចូលសាំង កើន ៨,៧% ម៉ាស៊ូត កើន ១៧,២% និង សម្ភារៈសំណង់ កើន ១,៦%។ អតិរេកពាណិជ្ជកម្ម កើន ៦២,៩% ធៀបនឹងមួយឆ្នាំមុន ដល់ ៤៧០,២លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០១១ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ១៧,៦% ធៀបនឹងត្រីមាសមុន ឬ ៦,១% ធៀបនឹងមួយឆ្នាំមុន ដល់ ១៧៧៦,៦ពាន់លានរៀល ក្នុងនោះ ចំណូលចរន្តរួមចំណែក ៩៧,៩%។ ចំណូលចរន្តសរុប កើន ១៦,២% ធៀបនឹងត្រីមាសមុន ឬ ១០,៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៧៤០,១ពាន់លានរៀល។ ចំណូលពន្ធសរុប (ស្មើនឹង ៨៣,៦% នៃចំណូលចរន្ត) កើន ១៨,៣% ធៀបនឹងមួយឆ្នាំមុន ដល់ ១៤៥៤,៣ពាន់លានរៀល។ ចំណូលមិនមែនពន្ធ (ស្មើនឹង ១៦,៤% នៃចំណូលចរន្ត) ធ្លាក់ចុះ ១៦,២% មកត្រឹម ២៨៥,៨ពាន់លានរៀល។ នៅត្រីមាសនេះដែរ ចំណាយសរុបកើន ៦០,១% ធៀបនឹងមួយឆ្នាំមុន ដល់ ៣១១៥ពាន់លានរៀល។ ចំណាយមូលធន (៤៦,៤% នៃចំណាយសរុប) កើន ១១៣,៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៤៤៤,៩ពាន់លានរៀល ហើយចំណាយចរន្ត (៥៣,៦% នៃចំណាយសរុប) កើន ៣១,៥% ដល់ ១៦៧០,២ពាន់លានរៀល។ ចំណាយលើបៀវត្សរ៍ (៣៦,៤% នៃចំណាយចរន្តសរុប) កើន ៧,២% ធៀបនឹងមួយឆ្នាំមុន។ ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច កើន ១១០,៦% ដល់ ៤៨៧,៣ពាន់លានរៀល។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១២ អតិផរណាថ្លៃទំនិញគ្រប់មុខនៅទីក្រុងភ្នំពេញ កើនដល់ ៥,៥% ធៀបនឹង ៣,៦% នៅត្រីមាសទី១ ឆ្នាំមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៦,៩% ធៀបនឹង ៣,៩% កាលពីមួយឆ្នាំមុន ហើយថ្លៃដឹកជញ្ជូន កើន ៧,៨% ធៀបនឹង ៥,០% កាលពីឆ្នាំមុន។ នៅត្រីមាសទី១ នេះដែរ ប្រាក់រៀល ធ្លាក់ថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ១,៨% ទល់នឹងប្រាក់បាតថៃ និង ៣% ទល់នឹងប្រាក់ដុងវៀតណាម។ ប្រេងម៉ាស៊ូត ឡើងថ្លៃ ១៥,៦% ធៀបនឹងមួយឆ្នាំមុន ដល់ ៥១២០,២រៀល/លីត្រ ហើយសាំង ឡើងថ្លៃ ១៣,៦% ដល់ ៥៣៩៥,៨រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៤ ឆ្នាំ២០១១ ទ្រព្យសកម្មបរទេសសុទ្ធ កើន ១,១% ធៀបនឹងត្រីមាសមុន (៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៧.៨៩៣,៩ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១៦,១% (១០៧,៣% ធៀបនឹងមួយឆ្នាំមុន)។ ឥណទានដល់វិស័យឯកជន កើន ៧,១% (៣១,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៧.៥៥២,៨ពាន់លានរៀល ដែលជាសញ្ញារើបឡើងវិញនៃការផ្ដល់កម្ចីឲ្យវិស័យឯកជន និងឱកាសអាជីវកម្មថ្មីៗ។

---

១ អត្ថបទនេះរៀបរៀងដោយលោករ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវ កញ្ញា អ៊ួនរិមល និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## ស្ថានភាពក្រីក្រ

អង្កេតប្រចាំត្រីមាសជាទៀងទាត់របស់វិទ្យាស្ថាន CDRI កាលពីខែឧសភា ២០១២ បានរកឃើញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះស្ទើរតែគ្រប់ក្រុម បានកើនឡើងបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្រុមទាំងនោះមានជាអាទិ អ្នកជាក់ស៊ីក្លូ អ្នកលីសែង អ្នកស៊ីឈ្នួលធ្វើស្រែ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប កម្មករសំណង់មានជំនាញ និងកម្មករសំណង់គ្មានជំនាញ ហើយក្នុងនោះ ក្រុមអ្នកជាក់ស៊ីក្លូ អ្នកលីសែង និងអ្នករត់ម៉ូតូឌុប មានប្រាក់ចំណូលកើនខ្លាំងជាងគេ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នកជាក់ស៊ីក្លូ ស្ទុះឡើង ២៩% ដល់ ១០.៦៨៦រៀល នៅខែឧសភា។ ចំណាយប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគេ កើន ១៥% លើសពី កម្រិត ៤៥៤៣រៀល កាលពីខែឧសភា ២០១១។ ក្នុងចំណោមអ្នកជាក់ស៊ីក្លូឆ្លើយសម្ភាសន៍ មានតែ ១២% ប៉ុណ្ណោះ ដែលមានស៊ីក្លូផ្ទាល់ខ្លួន ចំណែកឯអ្នកផ្សេងទៀតត្រូវជួលពីគេ។ ចំនួនអ្នកជាក់ស៊ីក្លូដេកតាមចិញ្ចើមថ្នល់ ឬនៅក្នុងវត្ត ធ្លាក់ចុះមកត្រឹម ៦៥% ធៀបនឹង ៦៨% កាលពីខែឧសភា ឆ្នាំ២០១១។ ជាមធ្យមពួកគេប្រកបរបរជាអ្នកជាក់ស៊ីក្លូ បាន ៩ឆ្នាំហើយ។

ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើន ២៩% ធៀបនឹងមួយឆ្នាំមុន ដល់ ១២.៧១៣រៀល ហើយចំណាយរបស់ពួកគេកើន ១៥% ពី ៥៤៥៥រៀល ដល់ ៦២៥៥រៀល/ថ្ងៃ។ អ្នកលីសែងផ្តល់សម្ភាសន៍ ៩២% ប្រាប់ថា ពួកគេជួលផ្ទះមួយនៅរួមគ្នា ១០នាក់ជាមធ្យម ហើយ ៥% ប្រាប់ថា ស្នាក់នៅតាមចិញ្ចើមថ្នល់ ឬនៅវត្ត និង ៣% ទៀត ប្រាប់ថា នៅតាមផ្ទះសាច់ញាតិ។ ម្យ៉ាងទៀតមាន ៧២% ប្រាប់ថា ស្ថានភាពគ្រួសាររបស់ពួកគេបានប្រសើរជាងមុន ចាប់តាំងពីពេលប្រកបរបរនេះ ហើយ ២០% ទៀត ប្រាប់ថា ស្ថានភាពគ្រួសារនៅដដែល រីឯ ៨% ទៀតប្រាប់ថា កាន់តែយ៉ាប់ជាងមុន។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប កើន ២៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៣.៦១៦រៀល។ ក្នុងចំណោមអ្នករត់ ម៉ូតូឌុបផ្តល់សម្ភាសន៍ មាន ៩២% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារដែលមានសមាជិកជាមធ្យម ៥នាក់។ ពួកគេ ៤៨% បានចូលរៀនថ្នាក់ បឋមសិក្សា ៤២% បានចូលរៀនអនុវិទ្យាល័យ ៨% បានចូលរៀនវិទ្យាល័យ និង ២% មិនបានចូលរៀនទេ។

ចំពោះកម្មករសំណង់គ្មានជំនាញវិញ ប្រាក់ចំណូលពិតប្រចាំថ្ងៃ កើន ២៣% ពីកម្រិត ៩៤១៥រៀល កាលពីមួយឆ្នាំមុន។ ចំណូលរបស់កម្មករសំណង់មានជំនាញ កើនតែ ៣,៩% ប៉ុណ្ណោះ ពីកម្រិត ១២.៣៦៨រៀល កាលពីមួយឆ្នាំមុន។ កម្មករសំណង់គ្មានជំនាញ ៨៥% ជួលផ្ទះគេនៅ ក្នុងពេលធ្វើការនៅទីក្រុងភ្នំពេញ រីឯ ៨៤% នៃកម្មករសំណង់មានជំនាញ បានស្នាក់នៅក្នុងការដ្ឋានសំណង់។ មានតែ ១០% នៃកម្មករសំណង់មាន ជំនាញប៉ុណ្ណោះ ដែលបានដឹងពីវត្តមានសមាគមកម្មករសំណង់ ប៉ុន្តែគ្មានពួកគាត់ណាម្នាក់បានចូលជាសមាជិកទេ។

អ្នកលក់បន្លែតូចតាចមានចំណូលប្រចាំថ្ងៃកើនឡើង ១៥%។ ពួកគាត់ភាគច្រើន ចំណាយពេលច្រើននៅក្នុងផ្សារ គឺជាមធ្យមប្រហែល ៧ម៉ោង/ថ្ងៃ ព្រមទាំងត្រូវក្រោកពីម៉ោង ៣ ទៀបភ្លឺ ដើម្បីទិញបន្លែទុកលក់។ ពួកគាត់ត្រូវការមូលធនប្រហែល ៧០.០០០រៀល/ថ្ងៃ ដើម្បីដំណើរការអាជីវកម្ម ប៉ុន្តែមានអ្នកឆ្លើយសម្ភាសន៍ ៥៨% ប្រាប់ថា ចំនួននេះមិនគ្រប់គ្រាន់ទេ។ មានអ្នកលក់បន្លែតូចតាចតែ ២,៥% ប៉ុណ្ណោះ ដែលជាបុរស។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៧,៥% ដល់ ៦៤៣១រៀល ប៉ុន្តែចំណាយប្រចាំថ្ងៃថយចុះ ០,២% មកត្រឹម ២០៨៣រៀល។ ពួកគេ ៥០% ពុំមានដីធ្លីទេ ៤៥% មានដីតិចជាងមួយហិកតា ហើយ ៥% មានដីមួយហិកតា។ ៥៥% នៃអ្នកស៊ីឈ្នួលធ្វើស្រែដែលបានឆ្លើយសម្ភាសន៍ គិតថា ចំណូលរបស់ខ្លួន បានត្រឹមតែសម្រាប់ចិញ្ចឹមគ្រួសារប៉ុណ្ណោះ រីឯ ៤៥% ទៀត គិតថា វាមិនគ្រប់គ្រាន់ទេ ទោះបីគាត់ខំធ្វើការដល់ទៅ ៨ម៉ោង/ថ្ងៃ ជាមធ្យមក្តី។

ចំណូលប្រចាំថ្ងៃរបស់កម្មកររោងចក្រកាត់ដេរ កើន ៥,៦% ធៀបនឹងឆ្នាំមុន ដល់ ៨៣៩១រៀល ហើយក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៩៨% ជានារី។ ស្របតាមកំណើនសកម្មភាពក្នុងឧស្សាហកម្មកាត់ដេរ មានអ្នកផ្តល់សម្ភាសន៍ ៧២% ប្រាប់ថា ខ្លួនបានធ្វើការថែមម៉ោងជារឿយៗ ១៦% បានធ្វើការថែមម៉ោងម្តងម្កាល និង ១២% មិនដែលបានធ្វើការថែមម៉ោងទេ។ ម្យ៉ាងទៀតមានអ្នកផ្តល់សម្ភាសន៍ ៥៥% ប្រាប់ថា ចង់ប្តូរការងារ ព្រោះនៅរោងចក្រមិនអាចរកប្រាក់សន្សំសម្រាប់ពេលអនាគតទេ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់ អ្នករើសអេតចាយ រួមចុះ ៤,៦% ពី ៨៦៦១រៀល ក្នុងខែឧសភា ឆ្នាំ២០១១ ដោយសារថ្លៃ និងប្រភពរបស់អេតចាយ ថយចុះ។ ក្នុងចំណោមអ្នករើសអេតចាយឆ្លើយសម្ភាសន៍ មាន ៧៣% មកពីខេត្តព្រៃវែង ១២% មកពី ស្វាយរៀង ១០% មកពី តាកែវ ២,៥% មកពីពោធិ៍សាត់ និង ២,៥% មកពី កណ្តាល។ ពួកគេ ៨០% មកភ្នំពេញជាមួយនឹងគ្រួសារ រីឯ ២០% មកម្នាក់ឯង។


### Cambodia Development Review—2012 Subscription Rates

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..............................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed..............................................................

**International Subscription (Individual)**

| | | |
|---|---|---|
| ❐ Thailand, Laos, Vietnam | ❐ English edition ($25)* | ❐ Khmer edition ($15)* |
| ❐ Asia and Europe | ❐ English edition ($30)* | ❐ Khmer edition ($20)* |
| ❐ Americas and Africa | ❐ English edition ($35)* | ❐ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❐Mr ❐Ms ❐Dr ❐Other ..............................................................

First name: .............................. Last name: .............................. Position: ..............................

Organisation / Company: ..............................................................

Address (CCC Box if applicable): ..............................................................

City / Province: .............................................. Country: ..............................................

Telephone: .............................................. Fax: ..............................................

e-mail: .............................................. ❐ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១១*

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92.0 | 615.0 | 41.4 | 278.0 | 36.7 | 4.1 | 156.4 | 123.9 | 440.6 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 818.5 | 54.5 | 44.3 | 87.7 | 67.1 | 257.1 | 2361.0 | 174.9 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *90.1* | *21.3* | *29.3* | *50.0* | *57.1* | *108.4* | *109.7* | *118.7* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10,003.2 | 4432.0 | 121.6 | 0 | 1096.2 | 209.5 | 2229.2 | 264.1 | 722.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *3980.1* | *14.0* | *0* | *1087.4* | *107.9* | *2221.9* | *264.1* | *257.0* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10,570.9 | 5865.5 | 217.5 | 322.3 | 1220.6 | 280.72 | 2642.7 | 2748.9 | 1338.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -56.8 | 48.2 | 278.8 | -77.0 | 841.4 | 4.0 | -51.3 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | -44.5 | 452.0 | -16.6 | -71.3 | -44.2 | 1115.0 | 752.9 | 9.6 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 87.1 | 14.1 | 9.5 | 4.1 | 5.9 | 106.3 | 60.9 | 64.8 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 73.3 | 25.3 | 20.3 | 16.1 | 22.8 | 90.0 | 58.5 | 60.8 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 268.8 | 38.9 | 76.2 | 23.6 | 48.7 | 51.1 | 29.3 | 197.2 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 196.8 | 78.4 | 106.0 | 43.8 | 77.4 | 247.4 | 148.7 | 322.8 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -61.2 | 35.3 | -58.7 | 76.7 | 219.7 | -39.9 | 117.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | -82.4 | -14.2 | 58.7 | -14.8 | -61.7 | 215.6 | 40.29 | 637.1 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 1111.7 | 260.9 | 288.3 | 383.7 | 427.4 | 286.9 | 335.3 | 430.7 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 999.7 | 276.6 | 293.8 | 321.4 | 351.0 | 319.6 | 364.5 | 366.3 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 2111.5 | 537.5 | 582.0 | 705.1 | 778.4 | 606.5 | 699.8 | 797.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -21.4 | 8.3 | 21.2 | 10.4 | -22.1 | 15.4 | 13.9 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | 0.5 | 15.8 | 19.4 | 20.0 | 13.9 | 12.8 | 20.2 | 13.0 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 2452.4 | 2922.8 | 3161.6 | 3209.5 | 2901.6 | 1045.4 | 1070.9 | 1017.6 | 1132.1 | 1455.6 | 1324.2 | 1280.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2352.8 | 2810.8 | 3050.2 | 3097.8 | 2565.3 | 938.3 | 942.7 | 880.5 | 964.2 | 1285.7 | 1129.2 | 1070.8 |
| *- សហរដ្ឋអាមេរិក* | 1555.6 | 1851.7 | 1959.9 | 1913.0 | 1512.6 | 531.9 | 524.8 | 464.5 | 466.7 | 619.4 | 504.7 | 493.3 |
| *- សហភាពអឺរ៉ុប* | 506.9 | 603.0 | 660.9 | 693.4 | 644.7 | 239.4 | 248.0 | 232.0 | 301.4 | 397.5 | 391.3 | 328.4 |
| *- អាស៊ាន* | 70.7 | 80.4 | 90.3 | 99.6 | 6.9 | 2.9 | 3.0 | 3.8 | 4.2 | 4.7 | 5.0 | 6.4 |
| *- ជប៉ុន* | 25.0 | 40.6 | 30.1 | 26.5 | 44.6 | 25.5 | 26.3 | 34.3 | 28.0 | 43.4 | 41.2 | 50.1 |
| *- ប្រទេសផ្សេងៗ* | 194.6 | 235.1 | 309.0 | 365.3 | 356.5 | 138.6 | 140.7 | 145.9 | 163.9 | 220.7 | 187.0 | 192.5 |
| កសិកម្ម | 61.3 | 59.7 | 55.6 | 44.6 | 73.1 | 44.9 | 72.3 | 74.0 | 167.9 | 98.9 | 92.0 | 80.5 |
| *- កៅស៊ូ* | 36.7 | 41.5 | 41.0 | 35.8 | 51.6 | 25.4 | 38.1 | 49.9 | 48.6 | 56.1 | 43.1 | 40.3 |
| *- ឈើ* | 10.3 | 8.6 | 8.7 | 3.4 | 3.5 | 8.8 | 18.7 | 6.2 | 16.8 | 16.1 | 9.7 | 8.9 |
| *- ត្រី* | 10.1 | 5.9 | 3.2 | 2.3 | 4.0 | 0.5 | 0.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 |
| *- ផ្សេងៗ* | 4.2 | 3.7 | 2.7 | 3.1 | 14.0 | 10.2 | 14.7 | 17.3 | 31.3 | 25.3 | 38.6 | 30.9 |
| ផ្សេងៗ | 38.3 | 52.3 | 55.8 | 67.1 | 263.2 | 62.2 | 55.9 | 63.2 | 70.8 | 71.0 | 102.9 | 128.8 |
| ការនាំចូលសរុប | 2513.0 | 512.2 | 554.8 | 1010.9 | 2239.0 | 731.3 | 677.1 | 728.7 | 918.8 | 763.1 | 877.5 | 809.9 |
| ក្នុងនេះ៖ សាំង | 40.2 | 38.8 | 58.7 | 70.1 | 91.2 | 27.6 | 30.5 | 62.0 | 76.7 | 73.8 | 81.8 | 70.7 |
| ម៉ាស៊ីត | 93.1 | 113.0 | 122.8 | 113.5 | 180.8 | 48.0 | 50.5 | 92.5 | 129.8 | 118.9 | 105.5 | 139.4 |
| សម្ភារៈសំណង់ | 134.7 | 56.5 | 69.0 | 77.8 | 49.7 | 16.7 | 13.8 | 11.8 | 12.7 | 11.6 | 12.0 | 13.5 |
| ផ្សេងៗ | 2245.0 | 303.9 | 304.3 | 749.5 | 1917.3 | 638.9 | 582.3 | 562.4 | 699.6 | 558.8 | 678.2 | 586.3 |
| ជញ្ជីងពាណិជ្ជកម្ម | -60.6 | 2410.6 | 2606.8 | 2198.6 | 662.6 | 314.1 | 393.8 | 289.0 | 213.3 | 692.5 | 446.7 | 470.2 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 30.9 | 0.5 | -6.6 | 9.5 | 33.3 | -12.2 | -5.2 |
| ការនាំចេញសរុប | - | - | - | - | - | 27.3 | 2.4 | -5.0 | 11.3 | 28.6 | -9.0 | -3.3 |
| ការនាំចូលសរុប | - | - | - | - | - | 29.8 | -7.4 | 7.6 | 26.1 | -16.9 | 15.0 | -7.7 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 16.1 | 19.5 | 8.5 | 1.6 | -17.2 | 75.2 | 62.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 |
| ការនាំចេញសរុប | 16.3 | 19.2 | 8.2 | 1.5 | -9.6 | 68.5 | 63.5 | 46.7 | 37.9 | 39.2 | 23.7 | 25.8 |
| ការនាំចូលសរុប | 189.6 | -79.6 | 8.3 | 82.2 | 121.5 | 51.0 | 27.1 | 44.1 | 63.1 | 4.4 | 29.6 | 11.1 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១១ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 4885.2 | 1341.1 | 1436.0 | 1675.0 | 1400.5 | 1564.3 | 1510.1 | 1776.6 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 4855.9 | 1330.9 | 1431.2 | 1570.5 | 1378.6 | 1563.0 | 1497.6 | 1740.1 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 4268.0 | 1143.8 | 1225.5 | 1229.6 | 1142.3 | 1367.5 | 1313.4 | 1454.3 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 3088.6 | 890.9 | 916.9 | 905.5 | 875.6 | 1095.3 | 996.6 | 1104.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 1064.7 | 253.0 | 308.6 | 324.1 | 266.7 | 272.3 | 316.7 | 350.2 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 702.1 | 187.1 | 205.7 | 340.9 | 236.3 | 195.5 | 184.2 | 285.8 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 64.6 | 20.2 | 19.5 | 14.5 | 10.6 | 18.6 | 15.2 | 19.4 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 408.0 | 102.9 | 127.0 | 121.7 | 130.0 | 138.9 | 144.2 | 175.6 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 228.2 | 61.0 | 59.2 | 204.8 | 95.7 | 37.9 | 24.9 | 90.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 29.3 | 10.2 | 4.8 | 104.5 | 21.9 | 1.3 | 12.5 | 36.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 7383.5 | 2154.8 | 2390.3 | 1945.4 | 1437.3 | 2025.2 | 2310.6 | 3115.0 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 2694.9 | 913.0 | 887.0 | 675.6 | 579.8 | 721.0 | 801.2 | 1444.9 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 4440.0 | 1168.1 | 1503.3 | 1269.8 | 857.5 | 1304.1 | 1509.4 | 1670.2 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 2012.0 | 545.6 | 562.4 | 567.4 | 401.0 | 531.6 | 629.7 | 608.3 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 871.4 | 253.2 | 401.5 | 231.4 | 257.4 | 450.9 | 323.3 | 487.3 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 1556.6 | 369.3 | 539.4 | 471.0 | 199.1 | 321.7 | 556.5 | 574.6 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -248.7 | -813.7 | -954.2 | -207.3 | -426.6 | -242.9 | -579.4 | -22.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | -2498.3 | 746.0 | 409.1 | 419.3 | -36.8 | -460.9 | -800.5 | -1338.4 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | 1746.1 | 194.1 | 343.3 | -21.6 | 544.4 | 576.9 | 272.9 | 985.0 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | -0.7 | 1.8 | 3.3 | 3.6 | 6.3 | 6.7 | 4.9 | 5.5 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | 33.1 | -0.3 | 1.9 | 4.1 | 3.9 | 7.6 | 8.2 | 6.2 | 6.9 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -10.7 | 3.2 | 3.1 | 5.0 | 7.3 | 8.8 | 6.3 | 7.8 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4140.5 | 4236.7 | 4122.6 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 121.1 | 138.3 | 137.3 | 132.7 | 133.8 | 135.2 | 131.1 | 130.2 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.4 | 21.4 | 21.1 | 19.9 | 19.6 | 19.8 | 19.4 | 19.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 113.1 | 147.8 | 165.7 | 147.9 | 181.5 | 204.6 | 203.8 | 204.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 3170.9 | 3936.6 | 4066.1 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5120.2 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3593.1 | 4415.5 | 4535.2 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 12,610.9 | 16,903.0 | 16,697.9 | 17,079.1 | 18099.9 | 17,695.2 | 17,893.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1573.0 | 1785.3 | 1984.8 | 2778.9 | 3199.2 | 3907.7 | 4961.6 | 5760.8 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -2252.0 | -2362.7 | -2120.4 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 10,532.0 | 11,859.1 | 12,479.8 | 13,331.2 | 13,909.0 | 15,290.6 | 16,385.7 | 17,552.8 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 18,267.1 | 18,887.8 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3115.1 | 3061.7 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 13,108.0 | 15,152.0 | 15,826.1 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 36.9 | 31.8 | 26.7 | 20.0 | 17.7 | 20.5 | 20.0 | 21.5 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 30.1 | 15.6 | 10.4 | 3.2 | 11.1 | 13.6 | 20.2 | 22.8 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 38.6 | 35.7 | 30.4 | 24.0 | 19.1 | 21.9 | 19.9 | 21.2 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2008 | 2009 | 2010 | 2011 | | | 2012 | | 2011 | 2012 | |
| | | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 8075 | 12,628 | 8091 | 9055 | 8292 | 9783 | 9348 | 9380 | 10686 | 6.7 | -11.8 | 28.9 |
| អ្នកលីសែង | 8588 | 9005 | 9549 | 9964 | 9861 | 10,465 | 11,554 | 10,804 | 12,713 | 16.0 | -3.4 | 28.9 |
| អ្នកលក់បន្លែតូចតាច | 8220 | 9926 | 8273 | 8266 | 8599 | 8405 | 7116 | 12292 | 9901 | -19.3 | 34.4 | 15.1 |
| អ្នករើសអេតចាយ | 5422 | 4652 | 5857 | 6698 | 8661 | 7557 | 10,347 | 7986 | 8266 | 56.1 | 15.2 | -4.6 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4482 | 4327 | 4646 | 5607 | 6066 | 5410 | 6271 | 6179 | 6261 | 15.1 | 0.4 | 3.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 8697 | 6197 | 5691 | 5984 | 7345 | 4577 | 4690 | 6431 | -6.8 | -2.4 | 7.5 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 6554 | 7085 | 7746 | 7950 | 8687 | 8620 | 8555 | 8391 | 8.5 | 2.9 | 5.6 |
| អ្នករត់ម៉ូតូឌុប | 10,634 | 15,691 | 10,685 | 10,623 | 10,630 | 11,146 | 12,971 | 12,256 | 13,616 | 26.2 | 7.1 | 28.1 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 8779 | 8343 | 8790 | 9415 | 10,526 | 9914 | 10,658 | 11,589 | 2.9 | -5.6 | 23.1 |
| កម្មករសំណង់មានជំនាញ | 11,154 | 12,710 | 12,487 | 11,952 | 12,368 | 12,676 | 15,013 | 13,824 | 12,847 | 23.9 | 10.7 | 3.9 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000.*
*Source: CDRI*